Australian Government

ParentsNext

# Participation Plan (ផែនការចូលរួម)

Participation Plan នេះរួមមានការណាត់ជួប និងសកម្មភាពទាំងឡាយដែលនឹងជួយខ្ញុំបំពេញគោលដៅការងារនាពេលអនាគតរបស់ខ្ញុំ។

ប្រសិនបើខ្ញុំមិនអាចចូលរួមការណាត់ជួប ឬសកម្មភាពណាមួយបានទេ ខ្ញុំយល់ព្រមទាក់ទងអ្នកផ្តល់សេវាកម្ម ParentsNext របស់ខ្ញុំមុនពេលការណាត់ជួប ឬសកម្មភាពដែលបានគ្រោងទុកកើតមានឡើង។

ខ្ញុំយល់ដឹងថា ខ្ញុំអាចស្នើសុំឱ្យមានការពិនិត្យឡើងវិញនូវ Participation Plan របស់ខ្ញុំ នៅពេលណាក៏បាន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរណាមួយនៅក្នុងកាលៈទេសៈរបស់ខ្ញុំ។

**គ្រប់ការឆ្លើយតបត្រូវផ្តល់ជាភាសាអង់គ្លេស**

**ឈ្មោះ៖**

**JSID:** **CRN:**

---

**គោលដៅ -** ទាំងនេះគឺជាគោលដៅការងាររបស់ខ្ញុំ។

**ការណាត់ជួប និងសកម្មភាពនានា -**

ការណាត់ជួប និងសកម្មភាពនានានៅក្នុងផែនការនេះ នឹងជួយឱ្យខ្ញុំឈានដល់គោលដៅរបស់ខ្ញុំ។

| | |
|---|---|
| **ឈ្មោះ៖** | **ព័ត៌មានលម្អិតរបស់អ្នកផ្តល់សេវាកម្ម៖**<br>អ្នកផ្តល់សេវាកម្ម ParentsNext |
| **ហត្ថលេខា៖**<br><br>**កាលបរិច្ឆេទ៖** | **ហត្ថលេខា៖**<br><br>**កាលបរិច្ឆេទ៖** |

# ព័ត៌មានដែលអ្នកចាំបាច់ត្រូវដឹង

## អំពី Participation Plan របស់អ្នក

អ្នកចូលរួម ParentsNext ជាទូទៅត្រូវបានតម្រូវឱ្យចូលក្នុង Participation Plan ដើម្បីជួយពួកគេក្នុងការរៀបចំផែនការ និងប្រុងប្រៀបសម្រាប់ការងារ។

Participation Plan របស់អ្នកចែងពីសកម្មភាពទាំងឡាយ ដែលអ្នក និងអ្នកផ្តល់សេវាកម្ម ParentsNext  របស់អ្នក យល់ព្រមថាអ្នកនឹងអនុវត្តដើម្បីជួយបំពេញគោលដៅការងារ នាពេលអនាគតរបស់អ្នក។

## តើខ្ញុំគួរធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំមិនអាចធ្វើអ្វីតាមដែលខ្ញុំបានយល់ព្រម?

ប្រសិនបើអ្នកមិនអាចធ្វើសកម្មភាពណាមួយនៅក្នុង Participation Plan របស់អ្នក ឬមិនអាចអញ្ជើញទៅកាន់ការណាត់ជួបណាមួយបានទេ សូមទាក់ទងអ្នកផ្តល់សេវាកម្ម ParentsNext របស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយអ្នកផ្តល់សេវាកម្ម ParentsNext របស់អ្នកប្រហែលជាអាចរៀបចំការណាត់ជួបមួយផ្សេងទៀត ដើម្បីឱ្យអ្នកអាចចូលរួមសកម្មភាព ឬការណាត់ជួបរបស់អ្នក។

ប្រសិនបើអ្នកមិនចូលរួមក្នុងការណាត់ជួបពីរលើកជាប់ៗគ្នា ចុះហត្ថលេខាលើ Participation Plan របស់អ្នកឬចូល រួមសកម្មភាពទាំងឡាយដែលបានព្រមព្រៀង ដោយគ្មានហេតុ ផលសមស្របទេនោះ អ្នកផ្តល់សេវាកម្ម ParentsNext របស់អ្នកអាចឱ្យអ្នកចាកចេញពី ParentsNext។

សូមកត់សម្គាល់ថា ការចូលរួមដោយស្ម័គ្រចិត្តរបស់អ្នកនៅក្នុង ParentsNext នឹងមិនប៉ះពាល់ដល់ប្រាក់ឧបត្ថម្ភលើប្រាក់ចំណូលណាមួយ ដែលអ្នកអាចនឹងទទួលបាននោះទេ។

## ចុះប្រសិនបើខ្ញុំមិនយល់ស្របនឹងការសម្រេចដែលបានធ្វើឡើង?

ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសំរេចដែលអ្នកផ្តល់សេវាកម្ម ParentsNext របស់អ្នកបានធ្វើឡើងអំពី Participation Plan របស់អ្នក ឬអ្នកមានការព្រួយបារម្ភអំពីសេវាកម្មដែលអ្នកបានទទួល អ្នកអាចពិភាក្សាពីកង្វល់របស់អ្នកជាមួយអ្នកផ្តល់សេវាកម្ម ParentsNext របស់អ្នក ឬទាក់ទង Department of Employment, Skills, Small and Family Business National Customer Service Line តាមទូរស័ព្ទលេខ 1800 805 260។

ប្រសិនបើអ្នកមិនពេញចិត្តនឹងការឆ្លើយតបដែលអ្នកទទួលបាន អ្នកអាចលើកយកបញ្ហានេះបន្ថែមទៀត ដោយទាក់ទង Commonwealth Ombudsman(ការិយាល័យស៊ើបអង្កេតបណ្តឹងតវ៉ាសហព័ន្ធ) តាមទូរស័ព្ទលេខ 1300 362 072។

## សិទ្ធិឯកជន

ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកត្រូវបានការពារដោយច្បាប់ រួមមានច្បាប់ *Privacy Act 1988 (ច្បាប់សិទ្ធិឯកជន ឆ្នាំ១៩៨៨)*។ ព័ត៌មានអាចត្រូវបានគេប្រមូល ប្រើប្រាស់ ឬផ្សព្វផ្សាយនៅកន្លែងដែលអ្នកផ្តល់ការអនុញ្ញាត ឬកន្លែងដែលច្បាប់អនុញ្ញាត។

យើងបានផ្តល់ជូនអ្នកនូវព័ត៌មានស្តីពីសិទ្ធិឯកជនសំខាន់ៗ អំពីការប្រមូល ការប្រើប្រាស់ នងការលាតត្រដាងនូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ ព័ត៌មានបន្ថែមអាចរកបានពី៖

- www.employment.gov.au/privacy
- អ្នកផ្តល់សេវាកម្មរបស់អ្នក
- Services Australia
- Office of the Australian Information Commissioner នៅតាមវិបសៃថ៍  www.oaic.gov.au

វាជាការសំខាន់ដើម្បីធ្វើឱ្យប្រាកដថា អ្នកបានអាន និងយល់ដឹងពីព័ត៌មាននេះ។